**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៩ ស.សរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

## សម្រេច

**ប្រការ១.-**

ត្រូវបានផ្លាស់ប្ដូរសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការ អនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅរាជធានី ខេត្តមួយចំនួនដូចខាងក្រោម៖

| | |
|---|---|
| ១. ឯកឧត្ដម ដុន វ៉ាត | អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តកំពង់ឆ្នាំង មកជាសមាជិកក្រុមការងារខេត្តកំពត |
| ២. ឯកឧត្ដម សំ សិរីកេន៍ | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម ពីសមាជិកក្រុមការងារខេត្តកំពង់ធំ មកជាសមាជិកក្រុមការងារខេត្តស្វាយរៀង |
| ៣.ឯកឧត្ដម ម៉ូវ ចរិយា | ប្រធានបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តព្រះសីហនុ មកជាសមាជិកក្រុមការងារខេត្តកណ្ដាល |
| ៤. ឯកឧត្ដម ស៊ុំ ម៉ាប់ | នាយកសាលាភូមិន្ទរដ្ឋបាល ក្រសួងមុខងារសាធារណៈ ពីសមាជិកក្រុមការងារខេត្តប៉ៃលិន មកជាសមាជិកក្រុមការងារខេត្តតាកែវ |
| ៥. ឯកឧត្ដម សេង សក្ដា | អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ពីសមាជិកក្រុមការងារខេត្តប៉ៃលិន មកជាសមាជិកក្រុមការងារខេត្តតាកែវ |
| ៦. ឯកឧត្ដម ជូវ សំភី | អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍលើវិស័យយុត្តិធម៌ ក្រសួងយុត្តិធម៌ ពីសមាជិកក្រុមការងារខេត្តស្ទឹងត្រែង មកជាសមាជិកក្រុមការងារខេត្តបាត់ដំបង |
| ៧. ឯកឧត្ដម គីម ហ៊ួរី | អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន ពីសមាជិកក្រុមការងារខេត្តកោះកុង មកជាសមាជិកក្រុមការងារខេត្តព្រៃវែង |
| ៨.ឯកឧត្ដម អ៊ូ ប៉ូរ៉ាត់ | អគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ មកជាសមាជិកក្រុមការងារខេត្តកណ្ដាល |
| ៩.ឯកឧត្ដម ឡាយ ម៉ារី | អគ្គនាយក នៃអគ្គនាយកដ្ឋាន ទូរគមនាគមន៍កម្ពុជា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តរតនគិរី |


www.pheakdeylaw.com

| | |
|---|---|
| | មកជាសមាជិកក្រុមការងារខេត្តកណ្តាល |
| ១០.ឯកឧត្តម ជា មានិត | អគ្គនាយក នៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តសៀមរាប មកជាសមាជិកក្រុមការងារខេត្តកណ្តាល |
| ១១.លោកស្រី មុំ ប្រណិត | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តកែប មកជាសមាជិកក្រុមការងារខេត្តកណ្តាល |
| ១២.លោក ព្រាប សុរិទ្ធី | អនុប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ទូរគមនាគមន៍បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តកំពង់ធំ មកជាសមាជិកក្រុមការងារខេត្តកណ្តាល |
| ១៣.លោក ប្រាក់ សៀងអាន | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ មកជាសមាជិកក្រុមការងារខេត្តកណ្តាល |
| ១៤.លោក ហេង គា | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តឧត្តរមានជ័យ មកជាសមាជិកក្រុមការងារខេត្តកណ្តាល |
| ១៥.លោក សូ ឃុនវិរក្ស | អនុប្រធានលេខាធិការដ្ឋានបញ្ញត្តិករ ទូរគមនាគមន៍កម្ពុជា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងាររាជធានីភ្នំពេញ មកជាសមាជិកក្រុមការងារខេត្តកណ្តាល |
| ១៦. លោក លឹម ណេម៉ូ | អគ្គាធិការរង នៃអគ្គាធិការដ្ឋានក្រសួងធនធានទឹក និងឧតុនិយម ពីសមាជិកក្រុមការងារខេត្តឧត្តរមានជ័យ មកជាសមាជិកក្រុមការងារខេត្តកណ្តាល |
| ១៧. លោក យក់ ប៊ុនស៊ន | អគ្គាធិការរង នៃអគ្គាធិការដ្ឋានក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពីសមាជិកក្រុមការងារខេត្តរតនគិរី មកជាសមាជិកក្រុមការងារខេត្តមណ្ឌលគិរី |
| ១៨. លោក មុំ ចន្ទតារ៉ា | អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពីសមាជិកក្រុមការងារខេត្តមណ្ឌលគិរី មកជាសមាជិកក្រុមការងារខេត្តរតនគិរី |



www.pheakdeylaw.com

| | |
|---|---|
| ១៩. លោក ឃិន សុវលក្ខណ៍ | អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ពីសមាជិកក្រុមការងារខេត្តរតនគិរី មកជាសមាជិកក្រុមការងារខេត្តត្បូងឃ្មុំ |
| ២០. លោក គឹម ណុង | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន ពីសមាជិកក្រុមការងារខេត្តព្រះវិហារ មកជាសមាជិកក្រុមការងារខេត្តបាត់ដំបង |
| ២១. លោក ប៉ោ និមល | អគ្គនាយករង នៃអគ្គនាយកដ្ឋានថាមពល ក្រសួងរ៉ែ និងថាមពល ពីសមាជិកក្រុមការងារខេត្តស្ទឹងត្រែង មកជាសមាជិកក្រុមការងារខេត្តកំពង់ចាម |
| ២២.លោក ចាប សុវណ្ណ | សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ពីសមាជិកក្រុមការងារខេត្តព្រះវិហារ មកជាសមាជិកក្រុមការងារខេត្តប៉ៃលិន |
| ២៣.លោក ផេង ស៊ីថា | សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ពីសមាជិកក្រុមការងារខេត្តប៉ៃលិន មកជាសមាជិកក្រុមការងារខេត្តព្រះវិហារ |
| ២៤. លោក អ៊ឹង ប៊ុនហុង | អនុប្រធាននាយកដ្ឋានបច្ចេកទេសថាមពល និងកិច្ចការបរមាណូ ក្រសួងរ៉ែ និងថាមពល ពីសមាជិកក្រុមការងារខេត្តមណ្ឌលគិរី មកជាសមាជិកក្រុមការងារខេត្តកំពង់ចាម |

**ប្រការ២ .-**

ត្រូវបានសម្រួលពីសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តមួយចំនួនដូចខាងក្រោម៖

| | |
|---|---|
| ១.ឯកឧត្តម គង់ សេង | សមាជិកទី១ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិកក្រុមការងារខេត្តព្រៃវែង សម្រួលចេញពីសមាជិកក្រុមការងារខេត្តស្វាយរៀង |
| ២.ឯកឧត្តម អោក បូរ៉ា | អគ្គនាយក ប្រៃសណីយ៍កម្ពុជាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិកក្រុមការងារខេត្តកណ្តាល សម្រួលចេញពីសមាជិកក្រុមការងារខេត្តកែប និងខេត្តតាកែវ |

៣. លោក ហ៊ុយ ភិរក្ស — អគ្គនាយករង នៃអគ្គនាយកដ្ឋានទេសចរណ៍ ក្រសួងទេសចរណ៍ សមាជិកក្រុមការងារខេត្តរតនគិរី សម្រួលចេញពីសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ

៤. លោក ផ្លុង ធឿន — អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ សមាជិកក្រុមការងារខេត្តកំពង់ធំ សម្រួលចេញពីសមាជិកក្រុមការងារខេត្តឧត្តរមានជ័យ

៥.លោក សៀង សិទ្ធី — អនុប្រធានលេខាធិការដ្ឋាន បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិកក្រុមការងារខេត្តប៉ៃលិន សម្រួលចេញពីសមាជិកក្រុមការងារខេត្តបន្ទាយមានជ័យ

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលរាជធានី ខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៤

**ត.ប នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com